# សេវាកម្ម Medi-Cal សំរាប់ក្មេងៗនិងមនុស្សពេញវ័យនៅក្មេងទាំងឡាយៈ

## ការពិនិត្យដំបូងនិងតាមពេលកំណត់ ការវិភាគរោគសញ្ញានិងការព្យាបាល

### សេវាកម្មសុខភាពផ្លូវចិត្តទាំងឡាយ

---

**សេចក្តីជូនដំណឹងនេះគឺសំរាប់ក្មេងៗនិងមនុស្សពេញវ័យនៅក្មេងទាំងឡាយ (ក្រោមអាយុ 21) ដែលមានសិទ្ធិចូលរួមសំរាប់សេវាកម្ម Medi-Cal EPSDT ទាំងឡាយនិងអ្នកផ្តល់ការថែទាំឬអាណាព្យាបាលទាំងឡាយរបស់ពួកគេ**

---

## តើសេវាកម្ម EPSDT ទាំងឡាយគឺជាអ្វី?

- សេវាកម្មសុខភាពផ្លូវចិត្ត EPSDT ទាំងឡាយគឺជាសេវាកម្ម Medi-Cal ទាំងឡាយដែលកែតម្រូវ ឬធ្វើអោយបញ្ហាសុខភាពផ្លូវចិត្តប្រសើរឡើង ដែលគ្រូពេទ្យរបស់លោកអ្នក ឬអ្នកផ្តល់ការថែទាំសុខភាពដទៃទៀតរកឃើញ ទោះបីជាបញ្ហាសុខភាពមិនបាត់ទៅទាំងស្រុង ។ សេវាកម្មសុខភាពផ្លូវចិត្ត EPSDT ទាំងឡាយត្រូវបានផ្តល់ដោយក្រសួងសុខភាពផ្លូវចិត្តស្រុកទាំងឡាយ ។
- បញ្ហាទាំងឡាយនេះអាចរួមមាន ភាពសោកសៅ ភាពព្រួយបារម្ភ ឬកំហឹងដែលធ្វើអោយជីវិតលោកអ្នកពិបាក ។
- **លោកអ្នកត្រូវតែមានអាយុក្រោម 21 ហើយមាន Medi-Cal ទំហំពេញលេញដើម្បីទទួលបានសេវាកម្មទាំងឡាយនេះ ។**

## របៀបទទួលយកសេវាកម្ម EPSDT នានាសំរាប់ខ្លួនលោកអ្នក (ក្រោមអាយុ 21) ឬកូនរបស់លោកអ្នក

សួរគ្រូពេទ្យរបស់លោកអ្នក ឬមន្ទីរព្យាបាលរោគអំពីសេវាកម្ម EPSDT ទាំងឡាយ ។ លោកអ្នកឬកូនរបស់លោកអ្នកអាចទទួលសេវាកម្មទាំងឡាយនេះ ប្រសិនបើលោកអ្នកឬគ្រូពេទ្យរបស់លោកអ្នក ឬអ្នកផ្តល់ការថែទាំសុខភាពផ្សេងទៀត មន្ទីរព្យាបាលរោគ (ដូចជា Child Health and Disability Prevention Program) ឬក្រសួងសុខភាពផ្លូវចិត្តស្រុកយល់ស្របថាអ្នកឬកូនរបស់លោកអ្នកត្រូវការពួកវា ។ លោកអ្នកអាចទូរស័ព្ទផងដែរទៅក្រសួងសុខភាពផ្លូវចិត្តស្រុករបស់លោកអ្នកដោយផ្ទាល់ ។ ការហៅទូរស័ព្ទគឺឥតគិតថ្លៃ ។

## ប្រភេទនៃសេវាកម្ម EPSDT ទាំងឡាយ

សេវាកម្មមួយចំនួនលោកអ្នកអាចទទួលពីក្រសួងសុខភាពផ្លូវចិត្តស្រុកគឺ:

- ការព្យាបាលជាបុគ្គល
- ការព្យាបាលជាក្រុម
- ការព្យាបាលជាគ្រួសារ
- ការប្រឹក្សាវិបត្តិ
- ការគ្រប់គ្រងសំណុំរឿង
- កម្មវិធីថ្ងៃពិសេសទាំងឡាយ
- ថ្នាំសុខភាពផ្លូវចិត្តរបស់លោកអ្នក

សេវាកម្មការប្រឹក្សានិងការព្យាបាលទាំងឡាយអាចត្រូវបានផ្តល់នៅតាមផ្ទះ នៅតាមសហគមន៍ ឬនៅក្នុងតាមកន្លែងផ្សេងទៀត ។

ក្រសួងសុខភាពផ្លូវចិត្តស្រុកនិងគ្រូពេទ្យរបស់លោកអ្នកឬអ្នកផ្តល់សេវាកម្មនឹងសំរេចចិត្តថាតើសេវាកម្មទាំងឡាយដែលលោកអ្នកសុំគឺចាំបាច់ខាងវេជ្ជសាស្ត្រ ។

## ក្រសួងសុខភាពផ្លូវចិត្តស្រុកទាំងឡាយ *ត្រូវតែ*អនុម័តសេវាកម្ម EPSDT របស់លោកអ្នក ។

រាល់ក្រសួងសុខភាពផ្លូវចិត្តស្រុកមានលេខទូរស័ព្ទឥតគិតថ្លៃដែលលោកអ្នកអាចទូរស័ព្ទសំរាប់ព័ត៌មានបន្ថែមនិងដើម្បីស្នើររកសេវាកម្មសុខភាពផ្លូវចិត្ត EPSDT ទាំងឡាយ ។

## តើ EPSDT Therapeutic Behavioral Services គឺជាអ្វី?

Therapeutic Behavioral Services (TBS) គឺជាសេវាកម្មសុខភាពផ្លូវចិត្តជំនាញមុខ EPSDT មួយ ។ TBS ជួយក្មេងៗនិងមនុស្សពេញវ័យនៅក្មេងទាំងឡាយដែល:

- មានបញ្ហាអារម្មណ៍ធ្ងន់ធ្ងរ
- រស់នៅក្នុងស្ថានភាពសុខភាពផ្លូវចិត្ត ឬអាចនឹងមាន ឬ
- បានដេកពេទ្យថ្មីៗដោយបញ្ហាសុខភាពផ្លូវចិត្ត ឬអាចនឹងទៅដេកពេទ្យព្យាបាលវិកលចរិក ។

ប្រសិនបើលោកអ្នកទទួលសេវាកម្មសុខភាពផ្លូវចិត្តផ្សេងទៀតហើយនៅតែសោកសៅ ភ័យព្រួយ ឬខឹងខ្លាំង លោកអ្នកអាចមានគ្រូបង្រៀនសុខភាពផ្លូវចិត្តដែលមានការបណ្តុះបណ្តាលម្នាក់អោយជួយលោកអ្នក ។ មនុស្សនេះអាចជួយលោកអ្នកនៅពេលលោកអ្នកមានបញ្ហាទាំងឡាយណាដែលអាចធ្វើអោយលោកអ្នកខឹង រកាំចិត្ត ឬសោកសៅ ។ មនុស្សនេះនឹងមកផ្ទះរបស់លោកអ្នក ផ្ទះជាក្រុម ឬទៅជាមួយលោកអ្នកតាមការធ្វើដំណើរ ឬកម្មវិធីនានានៅក្នុងសហគមន៍ ។

ក្រសួងសុខភាពផ្លូវចិត្តស្រុកអាចប្រាប់លោកអ្នកនូវរបៀបសួររកការវាយតម្លៃ ដើម្បីមើលថាលោកអ្នកត្រូវការសេវាកម្មសុខភាពផ្លូវចិត្តទាំងឡាយ រួមទាំង TBS ។

## តើខ្ញុំអាចនិយាយជាមួយអ្នកណាអំពីសេវាកម្មសុខភាពផ្លូវចិត្ត EPSDT ទាំងឡាយ?

គ្រូពេទ្យរបស់លោកអ្នក ពេទ្យព្យាបាលវិកលចរិក ទីប្រឹក្សា អ្នកធ្វើការសង្គមកិច្ច ឬអ្នកផ្តល់សេវាកម្មសង្គមកិច្ចឬសុខភាពផ្សេងទៀតអាចជួយលោកអ្នកក្នុងការរកសេវាកម្មសុខភាពផ្លូវចិត្ត EPSDT ទាំងឡាយ ។ សំរាប់ក្មេងៗ ឬមនុស្សពេញវ័យនៅក្មេងទាំងឡាយនៅក្នុងផ្ទះជាក្រុម ឬជាកន្លែងរស់នៅមានគ្រឿងប្រដាប់ជួយអោយងាយស្រួល និយាយជាមួយបុគ្គលិកអំពីការទទួលសេវាកម្ម EPSDT ទាំងឡាយបន្ថែមទៀត ។

សំរាប់ក្មេងទាំងឡាយណានៅក្នុងការថែទាំចិញ្ចឹម ពិគ្រោះជាមួយមេធាវីដែលតុលាការចាត់តាំងអោយរបស់ក្មេងនោះទៅ ។ លោកអ្នកអាចទូរស័ព្ទទៅក្រសួងសុខភាពផ្លូវចិត្តស្រុករបស់លោកអ្នកដោយផ្ទាល់ផងដែរ ។ (មើលនៅក្នុងសៀវភៅទូរស័ព្ទសំរាប់លេខទូរស័ព្ទឥតគិតថ្លៃ ឬទូរស័ព្ទទៅការិយាល័យមន្ត្រីផ្លូវការដែលរដ្ឋាភិបាលចាត់តាំងដើម្បីស៊ើបអង្កេតនិងទទួលបណ្តឹងខាងសុខភាពផ្លូវចិត្ត Department of Health Care Services) ។

## ចុះបើខ្ញុំមិនទទួលសេវាកម្មទាំងឡាយដែលខ្ញុំចង់បានពីក្រសួងសុខភាពផ្លូវចិត្តស្រុករបស់ខ្ញុំ?

លោកអ្នកអាចដាក់ពាក្យបណ្តឹងជាមួយក្រសួងសុខភាពផ្លូវចិត្តស្រុករបស់លោកអ្នកបើពួកគេបដិសេធសេវាកម្ម  EPSDT ទាំងឡាយ ដែលត្រូវបានស្នើសុំដោយគ្រូពេទ្យឬអ្នកផ្តល់របស់លោកអ្នក ។ លោកអ្នកអាចដាក់ពាក្យបណ្តឹងផងដែរបើលោកអ្នកគិតថាលោកអ្នកត្រូវការសេវាកម្មសុខភាពផ្លូវចិត្តទាំងឡាយ ហើយអ្នកផ្តល់របស់លោកអ្នកឬក្រសួងសុខភាពផ្លូវចិត្តស្រុកមិនយល់ស្រប ។

ទូរស័ព្ទទៅលេខទូរស័ព្ទឥតគិតថ្លៃរបស់ក្រសួងសុខភាពផ្លូវចិត្តស្រុកដើម្បីនិយាយជាមួយអ្នកសម្របសម្រួលដំណោះស្រាយ បញ្ហា (សារទុក្ខ/បណ្តឹង)សំរាប់ព័ត៌មានបន្ថែមនិងជំនួយ ។ លោកអ្នកអាចទូរស័ព្ទផងដែរទៅអ្នកគាំទ្រសិទ្ធិរបស់អ្នកជម្ងឺទាំងឡាយនៅស្រុក ឬ Department of Health Care Services ការិយាល័យមន្ត្រីផ្លូវការដែលរដ្ឋាភិបាលចាត់តាំងដើម្បីស៊ើបអង្កេតនិងទទួលបណ្តឹងខាងសុខភាពផ្លូវចិត្ត ។

លោកអ្នកអាចសួររកសាវនាការរដ្ឋក្នុងរវាង 90 ថ្ងៃក្រោយពីការធ្វើអោយដំណើការបណ្តឹងរបស់ក្រសួងសុខភាពផ្លូវចិត្តស្រុកល្អិតល្អន់ ដោយធ្វើការណ៍មួយដូចតទៅនេះ:

- **ទូរស័ព្ទទៅ:** 1-800-952-5253 ឬសំរាប់ TTY 1-800-952-8349
- **ទូរសារ:** 916-651-5210 ឬ 916-651-2789
- **សរសេរទៅ:** California Department of Social Services,<br>State Hearings Division<br>P.O. Box 944243, Mail Station 9-17-37<br>Sacramento, CA 94244-2430.

## តើខ្ញុំអាចទទួលព័ត៌មានបន្ថែមទៀតនៅកន្លែងណា?

សំរាប់ព័ត៌មានបន្ថែមទៀតសូមទាក់ទងការិយាល័យដូចតទៅនេះតាមលេខទូរស័ព្ទទាំងឡាយនៅខាងក្រោម ។

**ក្រសួងសុខភាពផ្លូវចិត្តស្រុក**
**លេខទូរស័ព្ទប្រើដោយឥតគិតថ្លៃ**
មើលទៅក្នុងសៀវភៅទូរស័ព្ទតាមតំបន់លោកអ្នក

**Department of Health Care Services**
**ការិយាល័យមន្ត្រីផ្លូវការដែលរដ្ឋាភិបាលចាត់តាំងដើម្បីស៊ើបអង្កេតនិងទទួលបណ្តឹងខាងសុខភាពផ្លូវចិត្ត**
1-800-896-4042

**វិបសៃយ៍ Department of Health Care Services**

www.dhcs.ca.gov

សំរាប់ព័ត៌មានបន្ថែមទៀតអំពីសុខភាពផ្លូវចិត្តនិង ភ្សែឌុទ សូមទៅគេហទំព័រទាំងឡាយដូចតទៅនេះ:

www.dhcs.ca.gov/services/mh
www.dhcs.ca.gov/services/mh/pages/EPSDT.aspx